វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
The NGO Forum on Cambodia
ធ្វើការរួមគ្នាដើម្បីការប្រសើរឡើង
Working Together for Positive Change

# របាយការណ៍

# សិក្ខាសាលាថ្នាក់ជាតិស្តីអំពី
# ការព្រួយបារម្ភចំពោះគម្រោងទំនប់វារីអគ្គិសនី
# "ដុន សាហុង"




**ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៤**
PGCT **ភ្នំពេញ កម្ពុជា**

**សហការរៀបចំដោយ វេទិកាអង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជា និងសម្ព័ន្ធ ទន្លេកម្ពុជា**

**រៀបចំដោយ ៖ បណ្ឌិត យិន សុរិយា**

**កែសំរួលដោយ ៖ លោកស្រី ជា ផល្លីកា**

# សេចក្តីថ្លែងអំណរគុណ

សិក្ខាសាលាថ្នាក់ជាតិស្តីអំពី "ការព្រួយបារម្ភចំពោះគម្រោងទំនប់វារីអគ្គិសនី ដន សាហុង" ត្រូវបានរៀបចំឡើងដោយមានការគាំទ្រនិង ជួយជ្រោមជ្រែងពីស្ថាប័ន និងបុគ្គល ជាច្រើន រួមមាន គម្រោងទំនប់វារីអគ្គិសនី និង សិទ្ធិសហគមន៍ នៃ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (NGOF) និង សម្ព័ន្ធទន្លេកម្ពុជា (RCC)។ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះគណៈកម្មការរៀបចំទាំងអស់នេះ។

យើងខ្ញុំសូមថ្លែងអំណរគុណទៅដល់អ្នកចូលរួមទាំងអស់ដែលអញ្ជើញមកពីស្ថាប័នរដ្ឋ សង្គម ស៊ីវិល វិទ្យាស្ថានស្រាវជ្រាវ និងសហគមន៍ ដែលបានចូលរួម និងរួមចំនែកក្នុងសិក្ខាសាលានេះ។ យើងខ្ញុំ ក៏សូមថ្លែងអំណរគុណផងដែរដល់វាគ្មិន ដែលបានចែករំលែក បទពិសោធន៍ និងចំនេះដឹង ជាមួយអ្នក ចូលរួមរបស់យើង និងអ្នកដែលបានធ្វើអោយការសន្ទនារបស់យើងកាន់តែរស់រវើក និងមានអត្ថន័យ។ សូមថ្លែងអំណរគុណជាពិសេស និងដឹងគុណទៅដល់ម្ចាស់ជំនួយរបស់យើងគឺ អុកស្វាម អូស្រ្តាលី សំរាប់ជំនួយហិរញ្ញវត្ថុ ដល់ សិក្ខាសាលា និងការពិភាក្សានេះ។

សំខាន់ផងដែរ យើងខ្ញុំសូមថ្លែងអំណរគុណ ដល់បុគ្គលិករបស់យើង និងមិត្តរួមការងារ ដែលមកពី NGOF និង RCC ដែលបានរៀបចំ និងគាំទ្រដល់ការពិភាក្សាប្រព្រឹត្តិទៅដោយរលូន។ បើគ្មានការគាំទ្ររបស់ពួកគាត់ទេ ការពិភាក្សាថ្នាក់ជាតិរបស់យើងនិងជួបការលំបាកជាច្រើន។

# តារាងអក្សរកាត់

| | | |
|---|---|---|
| BDP | : | ផែនការអភិវឌ្ឍន៍អាង |
| CNMC | : | គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា |
| CSOs | : | អង្គការសង្គមស៊ីវិល |
| EIA | : | ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន |
| IR | : | អង្គការទន្លេអន្តរជាតិ |
| MFCB | : | ក្រុមហ៊ុនសាជីវកម្ម មេកា ហ្វីស បើរហែត |
| MIME | : | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល |
| MoE | : | ក្រសួងបរិស្ថាន |
| MRC | : | គណៈកម្មការទន្លេមេគង្គ |
| NGOF | : | វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា |
| OAU | : | អុកស្វាម អូស្ត្រាលី |
| RCC | : | សម្ពន្ធ័ទន្លេកម្ពុជា |
| SEA | : | ការវាយតំលៃហេតុប៉ះពាល់បរិស្ថានជាយុទ្ធសាស្ត្រ |
| TBEIA | : | ការវាយតំលៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន |
| WCD | : | គណៈកម្មការទំនប់ពិភពលោក |
| WWF | : | អង្គការសត្វព្រៃពិភពលោក |

# មាតិកា

**សេចក្តីថ្លែងអំណរគុណ** ........ i
**តារាងអក្សរកាត់** ........ ii
**មាតិកា** ........ iii
**សេចក្តីផ្តើម** ........ 1
**១. កម្មវិធីបើក** ........ 1
សុន្ទរកថាស្វាគមន៍ របស់ បណ្ឌិត តឹក វណ្ណារ៉ា នាយកប្រតិបត្តិ អង្គការ NGO Forum ........ 1
ចំណាប់អារម្មណ៍ តំណាងសហគមន៍ ........ 2
សុន្ទរកថាបើកកម្មវិធី ដោយឯកឧត្តម ទា ផុប អនុរដ្ឋលេខាធិការ ក្រសួងបរិស្ថាន ........ 2
**២. បទបង្ហាញ** ........ 3
ពត៌មានថ្មីៗទាក់ទងនឹង ទំនប់វារីអគ្គិសនី ដន សាហុង ដោយ ឯកឧត្តម តែ ណាវុធ អគ្គលេខាធិការ គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ........ 3
ទស្សនៈវិស័យអង្គកាសង្គមស៊ីវិល លើទំនប់វារីអគ្គិសនី ដនសាហុង: របាយការណ៍ពីទស្សនកិច្ចសិក្សា ដោយ បណ្ឌិត តឹក វណ្ណារ៉ា ........ 5
អនុសាសន៍ពីអង្គការសង្គមស៊ីវិល ........ 5
ផលប៉ះពាល់នៃទំនប់វារីអគ្គិសនី ដនសាហុង ទៅលើសត្វផ្សោតទន្លេមេគង្គ ដោយ Gerry Ryan, WWF ........ 6
សារៈសំខាន់នៃការបង្កើតការវាយតំលៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន ដោយ លោក ដាញ់ សេរី នាយកដ្ឋាន EIA នៃក្រសួងបរិស្ថាន ........ 6
ការវិភាគលើរបាយការណ៍វាយតំលៃហេតុផលប៉ះពាល់បរិស្ថាននៃទំនប់ ដន សាហុង ដោយ Ame Trandem, International Rivers (IR) ........ 7
សំនួរ និងចំលើយ ........ 8
**៣. ការពិភាក្សាតាមក្រុម: ការព្រួយបារម្ភនិងជំហានបន្ទាប់សម្រាប់ទំនប់ ដន សាហុង** ........ 9
លទ្ធផលពីក្រុមស្រាវជ្រាវ ........ 9
លទ្ធផលបទបង្ហាញពីក្រុម អង្គការមិនមែនរដ្ឋាភិបាល ........ 10
លទ្ធផលពីក្រុមសហគមន៍ ........ 10

ឧបសម្ពន្ធ័៖ ទស្សនៈទាន និងកម្មវិធី ........................................................................................................ 12
ឧបសម្ពន្ធ័ ៖ សេចក្តីថ្លែងការរួម ........................................................................................................ 17

## សេចក្តីផ្តើម

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (NGOF) សហការជាមួយ និង សម្ពន្ធ័ទន្លេកម្ពុជា (RCC) បានរៀបចំសិក្ខាសាលាថ្នាក់ជាតិមួយ ស្តីពី " ការព្រួយបារម្ភ ចំពោះគម្រោងទំនប់វារីអគ្គិសនី ដនសាហុង " ដែលមានសិក្ខាកាមចូលរួមទាំងអស់១២២នាក់ (ស្រ្តី ៤៥ នាក់) មកពី ភ្នាក់ងាររដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ ស្ថាបន័ស្រាវជ្រាវ អ្នកវិទ្យាសាស្រ្តជលសាស្រ្ត អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ និងសហគមន៍ បានចូលរួមពិភាក្សាពីសារៈសំខាន់នៃទន្លេមេគង្គ និងបញ្ហាប្រឈមមុខចំពោះការរស់នៅរបស់ពួកគេ ពីទំនប់វារីអគ្គិសនី ដន សាហុង។ កម្មវត្ថុសំខាន់នៃសិក្ខាសាលានេះគឺចែករំលែកពត៌មាន និងបង្កើនការយល់ដឹងពីទំនប់វារីអគ្គិសនី ដនសាហុង ហើយនិង ផលប៉ះពាល់សំខាន់របស់វាទៅដល់ជីវភាពរស់នៅរបស់សហគមន៍តាមដងទន្លេមេគង្គនិងទន្លេសាប។

## ១. កម្មវិធីបើក

### សុន្ទរកថាស្វាគមន៍ របស់ បណ្ឌិត តឹក វណ្ណារ៉ា នាយកប្រតិបត្តិ អង្គការ NGO Forum

បណ្ឌិត តឹក វណ្ណារ៉ា នាយកប្រតិបត្តិ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (NGOF) បានស្វាគមន៍អ្នកចូលរួមទាំងអស់។ នៅក្នុងសុន្ទរកថាស្វាគមន៍ លោកបានគូសបញ្ជាក់ពីសារៈសំខាន់ និងកម្មវត្ថុចំបងនៃសិក្ខាសាលាថ្នាក់ជាតិនេះ។ គោលបំនងនៃសិក្ខា សាលានៅថ្ងៃនេះ គឺចង់ដឹងពីការព្រួយបារម្ភពីដៃគូរពាក់ពន្ធ័ផ្សេងៗ និងសហគមន៍ជុំវិញគំរោងទំនប់វារីអគ្គិសនី ដើម្បីប្រមូលការព្រួយបារម្ភ និងបញ្ជូនទៅអាជ្ញាធរពាក់ពន្ធ័ក្នុងការធ្វើសេចក្តីសំរេចចិត្ត។

លោកក៏បានរាយការណ៍អំពីគំរោងទំនប់វារីអគ្គិសនី ដន សាហុង គឺស្ថិតនៅក្រោមការសិក្សាពីលទ្ធភាព និង ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន។ ទំនប់ ដន សាហុង ដែលមានសមត្ថភាព ២៦០ MW គឺជាគំរោងមួយក្នុងចំនោមគំរោងវារីអគ្គិសនីទាំង ១២ ដែលគ្រោងសាងសង់នៅលើតួទន្លេមេគង្គ ក្នុងប្រទេសឡាវ។ ទំនប់វារីអគ្គិសនី ដន សាហុង ដែលបានស្នើឡើងនេះស្ថិតនៅចំងាយ២គីឡូម៉ែត្រ ពីព្រំប្រទល់ ឡាវ-កម្ពុជា នៅក្នុងខេត្តចំប៉ាសាក់ ប្រទេសឡាវ។ អគ្គិសនីដែលផលិតបាននឹងត្រូវលក់ទៅឲ្យប្រទេសថៃ។ ប្រសិនបើទំនប់វារីអគ្គិសនី ដនសាហុង ត្រូវបានកសាង វានឹងរាំងខ្ទប់ចរន្តទឹកហូរធម្មជាតិ នៅក្នុងព្រែកហ៊ូសាហុង ដែលជា ផ្លូវទឹកចំបងនៃទន្លេមេគង្គ។ ទំនប់វារីអគ្គិសនី ដន សាហុង ដែលបានស្នើឡើងត្រូវបានវិនិយោគដោយក្រុមហ៊ុនវិនិយោគ (Mega First Corporation Berhad, MFCB) ជា

សាវជីកម្មដែលមានមូលដ្ឋាននៅប្រទេសម៉ាឡេស៊ី។ នៅខែតុលា ២០១៣ រដ្ឋាភិបាលឡាវ បានជូនដំនឹងដល់គណៈកម្មការទន្លេមេគង្គថា ទំនប់វារីអគ្គិសនី ដនសាហុង គឺមិនស្ថិតនៅលើតួទន្លេមេទេ ដូច្នេះហើយវាមិនចាំបាច់ទាមទារការពិគ្រោះយោបល់ ពីប្រទេសដែលជាសមាជិកនៃគណៈកម្មការទន្លេមេគង្គទេ។ គណៈកម្មការទន្លេមេគង្គបានបង្ហាញថា ព្រែក ដន សាហុង គឺជាផ្លូវទឹកសំខាន់ដូចដែលបានបង្ហាញនៅ ក្នុងឯកសារផ្សេងៗរបស់គណៈកម្មការទន្លេមេគង្គ រួមមាន ផែនការអភិវឌ្ឍន៍អាង (BDP) និង របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានជាយុទ្ធសាស្ត្រ (SEA) ដែលរដ្ឋាភិបាលឡាវក៏បានអនុមត័រួចផងដែរ។ រហូតមកដល់បច្ចុប្បន្ននេះ ប្រជាមានិតឡាវ មិនបានបង្ហាញចេតនារបស់ខ្លួនក្នុងការប្រឹក្សាជាមួយកម្ពុជា និងសហគមន៍ដែលរងផលប៉ះពាល់ដែលនៅតាមបណ្តោយទន្លេទេ។ បណ្ឌិត តឹក វណ្ណារ៉ា បានគូសបញ្ជាក់ថា សិក្ខាសាលាថ្នាក់ជាតិអំពីការព្រួយបារម្ភនៃទំនប់វារីអគ្គិសនី ដន សាហុង គឺមាន សារៈសំខាន់ក្នុងការកំនត់ការបារម្ភចំបងៗទាំងអស់របស់ដៃគូពាក់ពន្ធ័ និងសហគមន៍ ហើយនិងបង្ហាញ ការព្រួយទាំងអស់នេះទៅកាន់អាជ្ញាធរពាក់ពន្ធ័។ ជាចុងបញ្ចប់ លោក បានលើកទឹកចិត្តឲ្យសិក្ខាកាម ទាំងអស់ ចូលរួមនិងចែករំលែកការព្រួយបារម្ភរបស់ពួកគេ និងចូលរួមបង្កើតសេចក្តីថ្លែងការណ៍រួមនិងបញ្ជូនទៅអាជ្ញាធរពាក់ព័ន្ធ។

### ចំណាប់អារម្មណ៏ តំណាងសហគមន៍

តំណាងសហគមន៍ម្នាក់ត្រូវបានអញ្ជើញឲ្យបង្ហាញការព្រួយបារម្ភរបស់សហគមន៏ អំពីទំនប់វារីអគ្គិសនី ដន សាហុង។ នៅក្នុងសុន្ទរកថាស្វាគមន៍ តំណាងសហគមន៏បានគូសបញ្ជាក់ថាគំរោងទំនប់វារីអគ្គិសនីដែលបានស្នើឡើងទំនងជាប៉ះពាល់ដល់ជីវភាពរបស់សហគមន៍របស់យើង។ វានឹងប៉ះពាល់ដល់ការបំលាស់ទីរបស់ត្រី។ វាក៏ប៉ះពាល់ផងដែរដល់សត្វផ្សោតដែលជាចំនុចទាក់ទាញភ្ញៀវទេសចរណ៏។ វានឹងប៉ះពាល់ដល់គុណភាពទឹកនិងជីវិតរបស់យើង។ ដូច្នេះហើយ ខ្ញុំសុំអំពាវនាវឲ្យបញ្ឈប់គម្រោងនេះ។

### សុន្ទរកថាបើកកម្មវិធី ដោយឯកឧត្តម ទា ជុប អនុរដ្ឋលេខាធិការ ក្រសួងបរិស្ថាន

នៅក្នុងសុន្ទរកថាបើកកម្មវិធី **ឯកឧត្តម ទា ជុប** បានស្វាគមន៍អ្នកចូលរួមទាំងអស់ ដែលបានចូលរួមសិក្ខាសាលាថ្នាក់ជាតិនេះ។ ឯកឧត្តម ក៏បានអរគុណដល់ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (NGOF) និង សម្ពន្ធ័ទន្លេកម្ពុជា (RCC) ដែលបានរៀបចំវេទិកានិងការពិភាក្សាក្នុងចំនោមភាគីពាក់ពន្ធ័។ ឯកឧត្តមបានគូសបញ្ជាក់ថាអ្វីដែល វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (NGOF) និង សម្ពន្ធ័ទន្លេកម្ពុជា (RCC) ធ្វើថ្ងៃនេះគឺស្របនឹងផែនការរបស់រដ្ឋាភិបាល។ ឯកឧត្តមបានបន្ថែមថា ថ្មីៗនេះរ

ដ្ឋាភិបាលបានចាប់ផ្ដើមផ្សព្វផ្សាយទាក់ទងនិងវេទិកាសាធារណៈនិងការចូលរួមរបស់សាធារណៈជនក្នុងសកម្មភាពរបស់រដ្ឋាភិបាល។ ដូច្នេះហើយ រដ្ឋាភិបាលសូមគាំទ្រនិងលើកទឹកចិត្តដល់ សង្គមស៊ីវិលអោយមានវេទិកា និង ការពិភាក្សាជាមួយដៃគូពាក់ពន្ធ័។

ទាក់ទងទៅនឹងគំរោងទំនប់វារីអគ្គិសនីនៅប្រទេសឡាវ ឯកឧត្តម ទា ជុប បានឲ្យដឹងថា រាជរដ្ឋាភិបាលកម្ពុជា ជាមួយនិងរដ្ឋាភិបាលនៃប្រទេសសមាជិក នៃគណៈកម្មការទន្លេមេគង្គផ្សេងទៀត បានបញ្ជូនការប្រឆាំងជំទាស់ទៅនឹងគំរោងវារីអគ្គិសនីដែលបានស្នើឡើង នៅគ្រប់កំរិតទាំងអស់នៃកិច្ចប្រជុំ រួមមានកិច្ចប្រជុំរដ្ឋមន្ត្រីនិងនាយករដ្ឋមន្ត្រី។ ឯកឧត្តម បានបន្តថា ខែក្រោយ នឹងមានកិច្ចប្រជុំនាយករដ្ឋមន្ត្រីមួយ រវាងប្រទេសឡាវ កម្ពុជា វៀតណាម និងថៃ។ ឯកឧត្តមបានមានប្រសាសន៏ថារបៀបវារៈមួយនៃកិច្ចប្រជុំនឹងនិយាយអំពីទំនប់វារីអគ្គិសនី ដន សាហុង។ ដូច្នេះហើយសិក្ខាសាលាថ្នាក់ជាតិនៅថ្ងៃនេះបានប្រារព្ធចំពេលក្នុងការកំណត់ការព្រួយបារម្ភទាំងអស់ពីសំណាក់សហគមន៍ដែលរងផលប៉ះពាល់ និងអង្គការសង្គមស៊ីវិល។ ឯកឧត្តម ទា ជុប បានលើកទឹកចិត្តអ្នកចូលរួមទាំងអស់ឲ្យចែករំលែកការព្រួយបារម្ភទាំងអស់ ហើយ ឯកឧត្តម ទន្ទឹងរង់ចាំ ទទួលរបាយការណ៍ពីសហគមន៍ដែលប៉ះពាល់។ ចុងបញ្ចប់ ឯកឧត្តមបានប្រកាសបើក សិក្ខាសាលាស្ដីអំពីការព្រួយបារម្ភចំពោះទំនប់វារីអគ្គិសនី ដន សាហុង។

# ២. បទបង្ហាញ

## ពត៌មានថ្មីៗទាក់ទងនឹង ទំនប់វារីអគ្គិសនី ដន សាហុង ដោយ ឯកឧត្តម តែ ណាវុធ អគ្គលេខាធិការ គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា

ឯកឧត្តម តែ ណាវុធ បានសង្ខេប ជូនអ្នកចូលរួមអំពីទន្លេមេគង្គ គណៈកម្មការទន្លេមេគង្គ គោលការណ៍ណែនាំ និងគោលការណ៍នៃគណៈកម្មការទន្លេមេគង្គ សំរាប់ការដោះស្រាយជំលោះ។ ទន្លេមេគង្គគឺជាទន្លេមួយក្នុងចំនោមទន្លេដែលវែងជាងគេនៅក្នុងពិភពលោក ហូរឆ្លងកាត់ប្រាំមួយប្រទេសគឺ ប្រទេសចិន មីយ៉ាន់ម៉ា ឡាវ ថៃ កម្ពុជា និងចុះទៅប្រទេសវៀតណាម និង សមុទ្រចិនខាងត្បូង។ ទន្លេមេគង្គ សំបូរទៅដោយធនធានធម្មជាតិ ប្រពន្ធ័អេកូឡូស៊ី និងមច្ឆាជាតិដែលផ្ដល់ប្រូតេអ៊ីនដល់ប្រជា ជនរាប់លាននាក់ដែលពឹងអាស្រយ័លើទន្លេមេគង្គ។ ទន្លេមេគង្គគឺជាជំរកនៃប្រភេទសត្វជិតផុតពូជ និងប្រពន្ធ័អេកូឡូស៊ីជាច្រើន។

គណៈកម្មការទន្លេមេគង្គ(MRC) គឺជាភ្នាក់ងារអន្តររដ្ឋាភិបាល ដែលមានសមាជិក គឺ ប្រទេសថៃ ឡាវ កម្ពុជា និងវៀតណាម។ MRC ត្រូវបានបង្កើតឡើង នៅឆ្នាំ១៩៥៧ ជាមួយនឹងរដ្ឋសមាជិកចំនួនបួន រួមមាន ថៃ ឡាវ កម្ពុជា និងវៀតណាម សំរាប់ផលប្រយោជន៍ជាក់លាក់ទូទៅរបស់ពួកគេ ការគ្រប់គ្រងរួម

គ្នា នៃការបែងចែកធនធានទឹក និងការអភិវឌ្ឍប្រកបដោយចេរភាពនៃទន្លេមេគង្គ។ គណៈកម្មការទន្លេមេគង្គ(MRC) គឺជាអង្គភាពប្រឹក្សាយោបល់និងសំរបសំរួលក្នុងតំបន់ដែលគ្រប់គ្រងដោយក្រសួងធនធានទឹកនិងបរិស្ថាននៃ បណ្តាប្រទេសទាំងបួន។ គណៈកម្មការទន្លេមេគង្គ(MRC)មានគោលបំនងធ្វើឲ្យប្រាកដថាទឹកទន្លេមេគង្គត្រូវបានគ្រប់គ្រងយ៉ាងមានប្រសិទ្ធិភាពដែលផ្តល់ផលប្រយោជន៍ទៅដល់ប្រទេស សមាជិកទាំងអស់ប្រកបដោយសមធម៌ និងកាត់បន្ថយនូវផលប៉ះពាល់អវិជ្ជមានទៅលើប្រជាជនក្នុងតំបន់ និងបរិស្ថាននៅក្នុងអាងទន្លេមេគង្គក្រោម។

ទាក់ទងទៅនឹងទំនប់វារីអគ្គិសនី ដនសាហុង ឯកឧត្តម តែ ណាវុធ បានរៀបរាប់ថា នៅ ខែតុលា ប្រទេសឡាវ បានជូនដំណឹងដល់កម្ពុជានិងប្រទេសជាសមាជិកផ្សេងទៀត អំពីគំរោងរបស់ខ្លួនក្នុងការសាងសង់ទំនប់វារីអគ្គិសនីនៅ ព្រែក ដន សាហុង។ កម្ពុជារួមជាមួយនឹងប្រទេសជាសមាជិកផ្សេងទៀតបានប្រាប់ប្រទេសឡាវឲ្យផ្អាកការសាងសង់។ ប្រទេសកម្ពុជាបានតវ៉ាសំនើរនៃការសាងសង់ទំនប់វារីអគ្គិសនី ដន សាហុង ដោយបានអះអាងថា ដន សាហុង ស្ថិតនៅលើតួទន្លេមេនៃទន្លេមេគង្គតម្រូវឲ្យមានការប្រឹក្សាយោបល់ពីរដ្ឋជាសមាជិក។ កិច្ចប្រជុំមួយ ត្រូវបានប្រព្រឹត្តិទៅនៅខែមករា ឆ្នាំ២០១៤ នៅវៀងចន្ទ័ ប៉ុន្តែពុំមានកិច្ចព្រមព្រៀងត្រូវបានបង្កើតឡើងនោះទេ។ ចំនុចផ្ទុយគ្នានោះគឺថាប្រទេសឡាវអះអាងថាទំនប់វារីអគ្គិសនី ដន សាហុង ដែលបានស្នើ គឺស្ថិតនៅលើដៃទន្លេ ខណៈដែលកម្ពុជានិងប្រទេសជាសមាជិកដទៃទៀតអះអាងថា ទំនប់វារីអគ្គិសនីដែលបានស្នើស្ថិតនៅតួទន្លេមេនៃទន្លេមេគង្គ។ ចាប់តាំងពីពេលនោះមក មិនមានកិច្ចប្រជុំត្រូវបានរៀបចំទេឡើយ។ ប្រទេសថៃជាប្រធាននៃគណៈកម្មាធិការ ប៉ុន្តែដោយសារប្រទេសថៃមានជំលោះក្នុងស្រុក ប្រទេសថៃមិនមានលទ្ធភាពកោះប្រជុំបានទេ។

ឯកឧត្តម តែ ណាវុធ បានរៀបរាប់បន្ថែមផងដែរថា កម្ពុជា ថ្មីៗនេះបានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់អន្តរក្រសួងបច្ចេកទេស។ ផ្អែកលើកិច្ចប្រជុំពិគ្រោះយោបល់បច្ចេកទេសជាមួយក្រសួងផ្សេងៗ យើងបានយល់ស្របថា ទំនប់វារីអគ្គិសនី ដនសាហុង គឺនៅលើតួទន្លេមេ មិនមែនដៃទន្លេទេ។ នេះតម្រូវឲ្យមានការពិគ្រោះយោបល់ជាមួយយើងនិង ប្រទេសជាសមាជិកដទៃទៀត ប្រសិនបើប្រទេសឡាវចង់សាងសង់ទំនប់វារីអគ្គិសនី។ យើងយល់ស្រប និងគាំទ្ររបាយការណ៍វាយតំលៃរបស់គណៈកម្មការទន្លេមេគង្គ ហើយនិង អនុសាសន៍នានា។ ការជីក ការបន្ទុះ និងសំលេងរំញ័រ នឹងប៉ះពាល់ដល់មច្ឆាជាតិ និងសត្វផ្សោត។ ការកែប្រែផ្លូវបំលាស់ទីត្រីគឺរចនាមិនត្រឹមត្រូវ។ ដូច្នេះហើយយើងតម្រូវឲ្យមានការវាយតំលៃហេតុប៉ះពាល់បរិស្ថានឆ្លងកាត់ព្រំដែន មុនពេលទំនប់អាចនឹងត្រូវសាងសង់។

ឯកឧត្តមក៏បានគូសបញ្ជាក់ថាសិក្ខាសាលាថ្នាក់ជាតិនៅថ្ងៃនេះអំពីទំនប់ ដន សាហុង ជាមួយសហគមន៍និងអង្គកាសង្គមស៊ីវិលដទៃទៀតគឺជាព្រឹត្តិការណ៍ដ៏ល្អ ក្នុងការកំនត់ការព្រួយបារម្ភ និងបញ្ហា

ប្រឈមនានា។ ឯកឧត្តមបានលើកទឹកចិត្តឲ្យមានការសន្ទនា និងការយល់ដឹងកាន់តែច្រើនថែមទៀត ពីទំនប់ ដន សាហុង ក្នុងចំនោមប្រជាជនកម្ពុជា អ្នកស្រាវជ្រាវ និងសាធារណជនទូទៅ។

## ទស្សនៈវិស័យអង្គកាសង្គមស៊ីវិល លើទំនប់វារីអគ្គិសនី ដនសាហុង: របាយការណ៍ពីទស្សនកិច្ចសិក្សា ដោយ បណ្ឌិត តឹក វណ្ណារ៉ា

ប្រទេសឡាវថ្មីៗនេះបានរៀបចំទស្សនកិច្ចសិក្សា សំរាប់ដៃគូពាក់ពន្ធ័ពីប្រទេសជាសមាជិក ដើម្បីទស្សនាតំបន់ទំនប់វារីអគ្គិសនីដែលបានស្នើ។ បណ្ឌិត តឹក វណ្ណារ៉ា រួមជាមួយ អ្នកដឹកនាំអង្គការសង្គម ស៊ីវិលដ៏ទៃទៀតបានចូលរួមដំនើរទស្សនកិច្ច។ ខាងក្រោមនេះគឺជាការរកឃើញសំខាន់ៗពីដំណើរទស្សនកិច្ចក្នុង ក្នុង

- ការវាយតំលៃហេតុប៉ះពាល់បរិស្ថានឆ្លងកាត់ប្រទេសមិនទាន់បានធ្វើ
- របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានបច្ចុប្បន្នមានចំណុចខ្វះខាតច្រើន
- វិធានការដែលស្នើឡើង ពិសេសការកែផ្លូវមច្ឆាឆ្លងកាត់គឺតូចនិងរាក់
- ប្រភេទត្រីមិនត្រូវបានកំនត់ និងសិក្សាឲ្យបានត្រឹមត្រូវទេ
- ការវាយតំលៃនៃផលប៉ះពាល់លើប្រពន្ធ័អេកូឡូស៊ី និងអេកូទេសចរណ៍មិនទាន់ធ្វើ

## អនុសាសន៍ពីអង្គការសង្គមស៊ីវិល

- ជំហររបស់អង្គការសង្គមស៊ីវិល គឺបញ្ឈប់ការសាងសង់ទំនប់វារីអគ្គិសនីរហូតដល់ប្រទេសឡាវ អនុវត្តសកម្មភាពដូចខាងក្រោម
  - បង្កើតការវាយតំលៃហេតុប៉ះពាល់បរិស្ថានដោយម៉ត់ចត់នៅលើផ្នែកខាងក្រោមនៃទន្លេ និងធនធានមច្ឆាជាតិ សហគមន៍ដែលប៉ះពាល់ ហើយនិងតំបន់ រ៉ាមសារ
  - ពិគ្រោះយោបល់ជាមួយប្រទេសជាសមាជិក
  - គណៈកម្មាការទន្លេមេគង្គត្រួតពិនិត្យឯករាជ្យលើគំរោងទំនប់វារីអគ្គិសនី ដនសាហុងដែលបានស្នើ
  - បង្កើតការវាយតំលៃហេតុប៉ះពាល់បរិស្ថានឆ្លងដែនដោយចូលរួមពីគ្រប់សហគមន៍ដែលប៉ះពាល់ និងដៃគូរទាំងអស់

o គោរពកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខានៅឆ្នាំ១៩៩៥ ដើម្បីជូនដំណឹង ពិគ្រោះយោបល់ និងវាយតំលៃហេតុប៉ះពាល់បរិស្ថាន

## ផលប៉ះពាល់នៃទំនប់វារីអគ្គិសនី ដនសាហុង ទៅលើសត្វផ្សោតទន្លេមេគង្គ ដោយ Gerry Ryan, WWF

លោក **Gerry Ryan** មកពី WWF បានធ្វើបទបង្ហាញលើផលប៉ះពាល់នៃទំនប់វារីអគ្គិសនី ដនសាហុង ដែលបានស្នើឡើង លើសត្វផ្សោតទន្លេមេគង្គ។ លោកបានគូសបញ្ជាក់ថា ទំនប់វារីអគ្គិសនីដែលបានស្នើឡើង នឹងប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សត្វផ្សោតទន្លេមេគង្គ ទាំងក្នុងដំណាក់កាល សាងសង់ និងប្រតិបត្តិការ។ អំឡុងពេល ដំនាក់កាលសាងសង់ ការជីកកកាយនឹងប៉ះពាល់ដល់សត្វផ្សោត ទីជម្រក និងចំនីរបស់វា។ សំលេងពីការសាងសង់នឹងបង្កគ្រោះថ្នាក់ដល់ប្រពន្ធ័ទទួលសំលេងរបស់សត្វផ្សោត។ សត្វផ្សោតប្រើប្រាស់ប្រពន្ធ័ទទួលសំលេងរបស់ពួកវាដើម្បីបំលាស់ទី និងស្វែងរកចំនីរបស់ពួកវា។ នៅពេលពួកវាមានបញ្ហាប្រពន្ធ័សំលេង ពួកវានឹងមិនមានលទ្ធភាពបំលាស់ទី និងស្វែងរកចំនីរបស់ពួកវា។ បន្ទាប់មកពួកវានឹងស្លាប់ដោយសារបញ្ហាប្រព័ន្ធទទួលសំលេង។

អំឡុងពេលដំនាក់កាលប្រតិបត្តិការ ទំនប់នឹងបញ្ចេញភក់ និងធ្វើឲ្យគុណភាពទឹកអាក្រក់ ដែលនឹងប៉ះពាល់ដល់ប្រពន្ធ័អេកូឡូស៊ី និងមច្ឆាជាតិ ដែលជាអាហារ សម្រាប់សត្វផ្សោត។ ទំនប់ដែលបានស្នើឡើង នឹងរាំងលំហូរទឹកធម្មជាតិ និងប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ចរាចររបស់ត្រី និងចំនីថយចុះ។ ការសិក្សាបានសរុបថាទំនប់វារីអគ្គិសនីដែលបានស្នើឡើងនៅដនសាហុង នឹងបង្កនូវហានិភ័យខ្ពស់ទៅដល់សត្វផ្សោត និងចំនីរបស់ពួកវា។ ផលប៉ះពាល់ប្រហែលអាចនឹងមិនបានកាត់បន្ថយ ។ វិធានការនិងផែនការដែលបានស្នើរឡើងនៅមានកំរិតនិងមិនច្បាស់លាស់នៅក្នុងរបាយការណ៍វាយតំលៃផលប៉ះពាល់។

## សារៈសំខាន់នៃការបង្កើតការវាយតំលៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន ដោយ លោក ដាញ់ សេរី នាយកដ្ឋាន EIA នៃក្រសួងបរិស្ថាន

លោក **ដាញ់ សេរី** មកពី នាយកដ្ឋាន EIA នៃក្រសួងបរិស្ថាន បានឲ្យនិយមន័យ ការវាយតំលៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន និងគូសបញ្ជាក់ពីមូលហេតុសំខាន់ក្នុងការបង្កើត ការវាយតំលៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន នៅក្នុងករណីទំនប់វារីអគ្គិសនី ដន សាហុង។ ការវាយតំលៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន គឺជាដំនើរការនៃការវាយតំលៃហេតុប៉ះពាល់បរិស្ថាននៃការអភិវឌ្ឍគំរោងដែលមានផលប៉ះពាល់

នៅក្នុងប្រទេសពីរ ឬច្រើន។ ផ្អែកលើគោលការណ៍ណែនាំរបស់គណៈកម្មាការទន្លេមេគង្គ ការវាយតំលៃហេតុប៉ះពាល់បរិស្ថានឆ្លងដែនត្រូវបានធ្វើឡើងដើម្បីបង្កើន និងលើកកម្ពស់ការសហការយ៉ាងរលូនក្នុងចំនោមបណ្តាប្រទេសនិងសហគមន៍ដែលរងផលប៉ះពាល់ ក៏ដូចជាការធានាថាបរិស្ថាននិងសង្គមត្រូវបានការពារយ៉ាងល្អ និងប្រសើរឡើង។ ការវាយតំលៃហេតុប៉ះពាល់បរិស្ថានត្រូវបានធ្វើតែនៅក្នុងដែនដីប្រទេសឡាវតែប៉ុណ្ណោះ មិនបានធ្វើនៅក្នុងប្រទេសកម្ពុជាឡើយ។ ទីតាំងគំរោងទំនប់វារីអគ្គិសនីដែលបានស្នើឡើង មានចំងាយត្រឹមតែ ២គីឡូម៉ែត្រប៉ុណ្ណោះ ពីព្រំប្រទល់ឡាវ-កម្ពុជា ជាទីដែលសំបូរទៅដោយប្រពន្ធ័អេកូឡូស៊ី ប្រព័ន្ធដីសើម តំបន់រ៉ាមសារ និងប្រភេទសត្វជិតផុតពូជជាច្រើន ដូចជា សត្វផ្សោត។ ទំនប់វារីអគ្គិសនីដែលបានស្នើឡើង នឹងមានផលប៉ះពាល់អវិជ្ជមាន ទៅលើប្រពន្ធ័អេកូឡូស៊ីរបស់ប្រទេសកម្ពុជា។ នៅចុងបញ្ចប់នៃបទបង្ហាញរបស់លោកក៏បានស្នើថាការវាយតំលៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន ការវិភាគលើការចំនាយ និងផលប្រយោជន៍ ព្រមទាំងការចូលរួមជាសាធារណៈ គួរត្រូវបានធ្វើឡើងនៅក្នុងប្រទេសកម្ពុជា ដើម្បីកំណត់ផលប៉ះពាល់អវិជ្ជមាន និងវិធានការសមស្របនានា។ លោកក៏បានផ្តល់អនុសាសន៍ថា យន្តការអំពីការចែករំលែកផលប្រយោជន៍រវាងប្រទេសឡាវ និងកម្ពុជាគួរត្រូវបានធ្វើឡើង ដើម្បីជួយដល់សហគមន៍ និងបរិស្ថានដែលទទួលផលប៉ះពាល់ពីគំរោង។

## ការវិភាគលើរបាយការណ៍វាយតំលៃហេតុផលប៉ះពាល់បរិស្ថាននៃទំនប់ ដន សាហុង ដោយ Ame Trandem, International Rivers (IR)

បទបង្ហាញរបស់ Ame ផ្តោតសំខាន់ ទៅលើការវិភាគ និងត្រួតពិនិត្យលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាននៃទំនប់ដនសាហុង។ ការត្រួតពិនិត្យលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាននៃទំនប់ ដន សាហុង បង្ហាញថា ទំនប់វារីអគ្គិសនីដែលបានស្នើឡើង នឹងទំនងជាមានផលប៉ះពាល់ធ្ងន់ធ្ងរទៅដល់មច្ឆាជាតិទន្លេមេគង្គ សត្វផ្សោត និងប្រពន្ធ័អេកូឡូស៊ី នៅពេលដែលការកសាងទំនប់នឹងបង្កើតជាសំលេង ហើយនឹងរារាំងច្រកផ្លូវទឹកចំបងដែលអនុញ្ញាតសំរាប់ការបំលាស់ទីត្រីនៅរដូវប្រាំង។ ការវិភាគក៏បានរកឃើញផងដែរថា របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានខ្វះទិន្នន័យមូលដ្ឋាន និងមិនស៊ីចង្វាក់គ្នា ដែលបង្ហាញថាស្ថាបន័អភិវឌ្ឍគម្រោងមិនមានចំនេះដឹង និងមិនយល់ពីសារៈសំខាន់នៃប្រពន្ធ័អេកូឡូស៊ីក្នុងតំបន់នេះ និងធ្វើការអះអាងគ្មានមូលដ្ឋានច្បាស់លាស់។ ទោះបីជាទំនប់វារីអគ្គិសនី ដន សាហុង មានចំងាយត្រឹម២គីឡូម៉ែត្រពីព្រំប្រទល់ប្រទេសឡាវ-កម្ពុជាក៏ដោយ ក៏គ្មានរបាយការណ៍ហេតុប៉ះពាល់ឆ្លងដែនណាមួយត្រូវបានពិចារណាឡើយ។ ច្បាប់អន្តរជាតិទាមទារឲ្យមានការវាយតំលៃហេតុប៉ះពាល់បរិស្ថានឆ្លងដែនសម្រាប់គំរោងដែលរំពឹងថានឹងមានផលប៉ះពាល់ធ្ងន់ធ្ងរក្នុងទីតាំងគម្រោង។

មានពត៌មាន/ទិន្នន័យមូលដ្ឋាន មិនគ្រប់គ្រាន់និងមិនច្បាស់លាស់អំពីជលផល និងការបំលាស់ទីនៃមច្ឆាជាតិនៃតំបន់នេះ។ វិធានការកាត់បន្ថយផលប៉ះពាល់ ដែលស្នើឡើងដោយក្រុមហ៊ុនមិនបានបង្ហាញភស្តុតាងដែលអាចអនុវត្តបាន ដែលនេះធ្វើឲ្យជលផល និងប្រជាជនក្នុងតំបន់ប្រឈមមុខនឹងហានិភ័យខ្ពស់។ ការកែផ្លូវបំលាស់ទីត្រីមិនបានត្រឹមត្រូវ។ ផ្អែកលើការវិភាគ កញ្ញាបានផ្តល់អនុសាសន៍មួយចំនួនរួមមាន

- ពិចារណាគ្រប់ជម្រើសរួមទាំងការមិនសាងសង់ទំនប់
- ស្វែងរកកន្លែងផ្សេងសម្រាប់សាងសង់ទំនប់។ តំបន់ ដន សាហុង និងតំបន់ល្បាក់ខោន សំបូរទៅដោយ ប្រពន្ធ័អេកូឡូស៊ី និងធនធានធម្មជាតិ។ បើគ្រាន់តែសាងសង់ទំនប់វារីអគ្គិសនីដែលមានកម្លាំងត្រឹមតែ ២៦០ មេហ្គាវ៉ាត់ ទំនប់វារីអគ្គិសនី ដន សាហុង អាចនឹងមិនមានតំលៃល្មមគ្រប់គ្រាន់ទៅលើផលប៉ះពាល់បរិស្ថាន សង្គម និងវប្បធម៌ទេ។
- រាល់ការសាងសង់ទាំងអស់គួរត្រូវបានបញ្ឈប់ភ្លាមៗ រង់ចាំរហូតដល់ការសិក្សាចាំបាច់ និងវិធានការ(ការវាយតំលៃហេតុប៉ះពាល់ឆ្លងដែន ការសិក្សាពត៌មានមូលដ្ឋានជលផល) ត្រូវបានធ្វើ និងដាក់ឲ្យដំនើរការសិន។

## សំនួរ និងចំលើយ

**សំនួរ** : ប្រសិនបើយើងសុំឲ្យប្រទេសឡាវ បញ្ឈប់គម្រោងទំនប់វារីអគ្គិសនី ដន សាហុង តើកម្ពុជានឹងបញ្ឈប់ការសាងសង់ទំនប់នៅស្ទឹងត្រែង និងក្រចេះផងដែរឬ?

**ចំលើយ** : វាគឺពិបាកណាស់សម្រាប់ខ្ញុំក្នុងការឆ្លើយថាតើយើងនឹងសាងសង់ទំនប់នៅស្ទឹងត្រែង/សំបូរ ឬយ៉ាងណា។ វាគឺមិនអាស្រយ័លើខ្ញុំឡើយ។ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលគឺកំពុងសិក្សាពីភាពដែលអាចទៅរួច និងស្នើសុំទៅនាយករដ្ឋមន្ត្រី។ វាអាស្រយ័ទៅលើ តម្រូវការ និងការផ្គត់ផ្គង់។ វាអាចនឹងមិនទាក់ទងទៅនឹងទំនប់វារីអគ្គិសនី ដន សាហុងឡើយ។

**សំនួរ** : តើអ្វីជាផលប្រយោជន៍សម្រាប់សហគមន៍ដែលរងផលប៉ះពាល់នៅក្នុងប្រទេសកម្ពុជា?

**ចំលើយ** : ការចែករំលែកផលប្រយោជន៍ អាស្រ័យទៅលើ ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន តើផលប៉ះពាល់អ្វីដែលយើងមាន? មានការអនុវត្តឫបទដ្ឋានអន្តរជាតិជាច្រើន សម្រាប់ការចែករំលែកផលប្រយោជន៍ជាសំណងទៅឲ្យសហគមន៍ដែលរងផលប៉ះពាល់។ ពួកគេអាចទទួលបានការងារកំឡុងពេលសាងសង់ ទទួលបានផ្លូវ និង អគ្គិសនី។ ផលប្រយោជន៍អាស្រ័យលើផលប៉ះពាល់ដែលបច្ចុប្បន្នយើងកំពុងពិភាក្សាអំពីផលប៉ះពាល់នេះ។ យើងទាំងអស់ត្រូវការអគ្គិសនី។ យើងយល់ថាប្រទេសឡាវត្រូវការអគ្គិសនីផងដែរ។ យើងដឹងហើយ អ្វីគ្រប់យ៉ាងវាមានទាំងគុណសម្បត្តិ និងគុណវិបត្តិ។ កិច្ចខិតខំប្រឹងប្រែងដល់ការចែករំលែកផលប្រយោជន៍ក្នុងតំបន់ត្រូវបានធ្វើឡើងដើម្បីធានាឲ្យបាននូវការចែករំលែកផលប្រយោជន៍ និង

ធានានូវចីរភាពនៃគម្រោងទំនប់វារីអគ្គិសនី។ ប្រហែលជាឡាវអាចលក់អគ្គិសនីមកឲ្យយើងក្នុងតំលៃដែលសមរម្យ។ **សំណង** : ឡាវមានយុទ្ធសាស្ត្រសំរាប់បញ្ហានេះ។ ពួកគេមិនផ្តល់ទិន្នន័យជាមូលដ្ឋានគ្រប់គ្រាន់។ កម្ពុជាអាចមាននឹងលំបាកក្នុងការសុំសំណង ពីព្រោះយើងខ្វះទិន្នន័យអំពីផលប៉ះពាល់។ ទោះជាយ៉ាងណាក៏ដោយ កម្ពុជាធ្វើល្អណាស់ដោយផ្តោតលើធនធានជលផល។ ខ្ញុំសង្ឃឹមថាកម្ពុជានឹងយកជំហរឹងមាំក្នុងពីរបីសប្តាហ៍នេះ។ យើងដឹងថា ផលប៉ះពាល់លើជលផលគឺមានទំហំធំធេងណាស់។ ហេតុអ្វីមិនសាងសង់នៅកន្លែងផ្សេងដែលមានផលប៉ះពាល់តិច តែបានទទួលអគ្គិសនីដូចគ្នា? ហេតុអ្វីបានជានៅតែសាងសង់ទំនប់ ដន សាហុង? ខ្ញុំទាយថាបុគ្គលមួយចំនួនបានទទួលផលប្រយោជន៍ពីគម្រោងនេះ។

**សំនួរ** : តើរដ្ឋាភិបាលកម្ពុជាមានជំហយ៉ាងដូចម្តេចចំពោះការសាងសង់ទំនប់វារីអគ្គិសនី ដន សាហុង?
**ចំលើយ** : រាជរដ្ឋាភិបាលកម្ពុជា មិនបានយល់ស្របជាមួយនឹងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ហើយបានទាមទារឲ្យមានការវាយតំលៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន។ យើងបានបង្ហាញពីការជំទាស់ជាផ្លូវការរបស់យើងទៅសមភាគីឡាវរបស់យើងនៅគ្រប់កិច្ចប្រជុំនិងព្រឹត្តិការណ៍ទាក់ទងនឹងទំនប់ ដន សាហុង។

## ៣. ការពិភាក្សាតាមក្រុម: ការព្រួយបារម្ភនិងជំហានបន្ទាប់សម្រាប់ទំនប់ ដន សាហុង

អ្នកចូលរួមត្រូវបានបែកចែកជាបីក្រុម ក្រុមស្រាវជ្រាវ ក្រុមសហគមន៍ និងក្រុមអង្គការមិនមែនរដ្ឋាភិបាល ដើម្បីពិភាក្សា លើសំនួរពីរសំខាន់ខាងក្រោម៖

1. អ្វីជាការព្រួយបារម្ភបីរបស់អ្នក ចំពោះគម្រោងដនសាហុង?
2. អ្វីជាវិធានការបីរបស់អ្នកក្នុងការដោះស្រាយបញ្ហាខាងលើ?

<u>លទ្ធផលពីក្រុមស្រាវជ្រាវ</u>

| **វិស័យ** | **ការព្រួយបារម្ភ** | **ដំនោះស្រាយ** |
|---|---|---|
| សេដ្ឋកិច្ច | ប៉ះពាល់សេដ្ឋកិច្ចជាតិ<br>បាត់បង់មច្ឆាជាតិ<br>បាត់បង់ថវិកា | សាងសង់ប្រពន្ធ័ធារាសាស្រ្ត<br>បច្ចេកទេសកសិកម្ម<br>តាមរយៈការសិក្សាពីហេតុប៉ះពាល់បរិស្ថាន (EIA) |
| សង្គម | សុខភាព<br>ការអប់រំ | ការវាយតំលៃហេតុប៉ះពាល់សង្គម<br>ពង្រឹងការអនុវត្តតាមអនុសាសន៍ពី EIA |

| | | |
|---|---|---|
| | សាមគ្គីភាពក្នុងសហគមន៍<br>ប្រពៃណីនិងវប្បធម៌ | ការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ |
| បរិស្ថាន | គុណភាពទឹក<br>ជីវចំរុះ<br>ការប្រែប្រួលអាកាសធាតុ | សិក្សាហេតុប៉ះពាល់បរិស្ថាន/ឆ្លងដែន (EIA or TBEIA)<br>ការស្រាវជ្រាវសកម្មដែលមានការចូលរួម |

<u>លទ្ធផលបទបង្ហាញពីក្រុម អង្គការមិនមែនរដ្ឋាភិបាល</u>

**ការព្រួយបារម្ភជាអាទិភាព**

1. ប្រជាជនខ្វះពត៌មានអំពីគម្រោងទំនប់វារីអគ្គិសនី
2. ការព្រួយបារម្ភរបស់សហគមន៍គឺមិនបានឮទៅដល់អាជ្ញាធរ
3. គ្មានការពិគ្រោះយោបល់ក្នុងចំនោមរដ្ឋាភិបាលទាំងបួន
4. ការវាយតំលៃហេតុប៉ះពាល់បរិស្ថានឆ្លងដែនមិនត្រូវបានធ្វើ
5. កង្វះការគាំទ្រពីអាជ្ញាធរដូចជាចំនេះដឹង និងការយល់ដឹង
6. រដ្ឋាភិបាលប្រហែលមិនបានឮនិងលើកឡើងពីការព្រួយបារម្ភសហគមន៍ដែលរងផលប៉ះពាល់

**ដំនោះស្រាយ**

1. ពន្យារពេលការសាងសង់គម្រោងរហូតដល់មានការសិក្សាការវាយតំលៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន និងវិធានការសមស្របដែលចាំបាច់ត្រូវបានបង្ហាញ
2. ធ្វើការវាយតំលៃហេតុប៉ះពាល់បរិស្ថានឆ្លងដែនដែលមានការចូលរួមនិងរៀបចំដោយប្រទេសពាក់ពន្ធ័និងអង្គការសង្គមស៊ីវិល និងសហគមន៍ដែលរងផលប៉ះពាល់
3. គោរពនិងអនុវត្តគោលការណ៍ណែនាំទាំង៧ និង គោលការណ៍គ្រឹះនៃគណៈកម្មការទំនប់ពិភពលោក (WCD) និង គោលការណ៍ណែនាំព្រមទាំងកិច្ចព្រមព្រៀងរបស់គណៈកម្មការទន្លេមេគង្គ
4. បង្កើនការយល់ដឹងជាសាធារណៈ
5. រៀបចំវេទិកាសហគមន៍ដើម្បីមានការសន្ទនាជាមួយនឹងអ្នកធ្វើការសំរេចចិត្ត
6. កំនត់យុទ្ធសាស្រ្ត ដើម្បីដាក់សម្ពាធទៅលើអ្នកវិនិយោគទុនដើម្បីពន្យារពេលគម្រោង

<u>លទ្ធផលពីក្រុមសហគមន៍</u>

**ការព្រួយបារម្ភ**

ទំនប់វារីអគ្គិសនី ដន សាហុង ដែលបានស្នើឡើង នឹងប៉ះពាល់ដល់៖

- ធនធានធម្មជាតិដែលប៉ះពាល់ដល់ជីវភាពរបស់យើង
- គុណភាពទឹក ប៉ះពាល់ផងដែរដល់មច្ឆាជាតិនិងសត្វ
- ប្រពៃណីនិងវប្បធម៌នៃសហគមន៍ក្នុងតំបន់ (ការតាំងទីលំនៅថ្មី និងការបំលាស់ទីលំនៅ)

**ដំនោះស្រាយ**

1. បង្កើនការយល់ដឹងទៅដល់សហគមន៍ក្នុងតំបន់
2. ស្នើសុំអង្គការសង្គមស៊ីវិលនិងអង្គការមិនមែនរដ្ឋាភិបាលឲ្យជួយគាំទ្រនិងរៀបចំសហគមន៍
3. បញ្ជូនញ្ញាតិទាមទាររបស់យើងទៅរដ្ឋាភិបាលដើម្បីបង្ហាញពីការព្រួយបារម្ភរបស់យើង

## ៤. សរុបសេចក្តីនិងចំនុចកម្មវិធី

សិក្ខាសាលាថ្នាក់ជាតិស្តីអំពីការព្រួយបារម្ភចំពោះទំនប់វារីអគ្គិសនី ដន សាហុង បានប្រព្រឹត្តិទៅយ៉ាងរលូន។ សេចក្តីថ្លែងការរួមគ្នាមួយបានត្រូវបង្កើតឡើងនិងអនុម័តពីសំនាក់អ្នកចូលរួមទាំងអស់។ សេចក្តីថ្លែងការរួមបានឆ្លុះបញ្ចាំង និងបញ្ចូលការព្រួយបារម្ភសំខាន់ៗ នៃភាគីពាក់ពន្ធ័និងសហគមន៍។ សមាជិកទាំងអស់បានយល់ស្របក្នុងការបញ្ជូនញ្ញាតិទាមទារទៅអាជ្ញាធរដែលពាក់ពន្ធ័ និងលោកនាយករដ្ឋមន្រ្តី ដើម្បីបញ្ជូនការព្រួយបារម្ភរបស់ពួកគេទៅរដ្ឋាភិបាលឡាវ។ អ្នកចូលរួមដែលមកពីសំនាក់សហគមន៍ដែលរងផលប៉ះពាល់ក៏បានយល់ស្របផងដែរក្នុងការទទួលយកការផ្តិតមេដៃគាំទ្រញ្ញតិពីសមាជិកសហគមន៍របស់ពួកគេ នៅពេលពួកគេត្រលប់ទៅផ្ទះ និងបញ្ជូនញ្ញតិរបស់ពួកគេទៅអាជ្ញាធរឲ្យបានមុនថ្ងៃទី៥ ខែមេសា ពេលដែល នាយករដ្ឋមន្ត្រីជួបប្រជុំគ្នានៅប្រទេសវៀតណាមខាងមុខ។

**ឧបសម្ព័ន្ធ៖ ទស្សនៈទាន និងកម្មវិធី**

## <u>ទស្សនទាន</u>
## សិក្ខាសាលាថ្នាក់ជាតិ ស្តីពី
## ការព្រួយបារម្ភណ៍ចំពោះគម្រោងទំនប់វារីអគ្គិសនី «ដន សាហុង»
## ថ្ងៃ២០ ខែមិនា ឆ្នាំ២០១៤
## ទីកន្លែង៖ មជ្ឈមណ្ឌលវប្បធម៌ភ្នំពេញ-កូរ៉េ (PGCT) រាជធានីភ្នំពេញ

### <u>១. សាវតា</u>

ទំនប់វារីអគ្គិសនី **ដន សាហុង** ដែលមានថាមពល ២៦០ម៉េហ្គាវ៉ាត់ គឺជាទំនប់មួយក្នុងចំណោមគម្រោងទំនប់វារីអគ្គិសនីទាំង១២ដែលគ្រោងសាងសង់នៅតួទន្លេមេនៃទន្លេមេគង្គក្រោម។ បច្ចុប្បន្នវាកំពុងត្រូវបានចាប់ផ្តើមសិក្សានិងដាក់សំណើសម្រាប់ការសាងសង់បន្ទាប់ពីទំនប់វារីអគ្គិសនី សាយ៉ាបូរី។ វាមានទីតាំងស្ថិតនៅចំងាយ ២ គីឡូម៉ែត្រ ពីព្រំដែនកម្ពុជា-ឡាវ ក្នុងខេត្ត ចំប៉ាសាក់ ប្រទេសឡាវ។ អគ្គិសនីបានពីទំនប់ ដន សាហុង ត្រូវបានគ្រោងទុកសំរាប់នាំចេញទៅកាន់ប្រទេសថៃ។ ប្រសិនបើទំនប់ត្រូវបានសាងសង់វានឹងរាំងខ្ទប់ដៃទន្លេ ហ៊ូ សាហុង ដែលជាដៃទន្លេដ៏ធំមួយដែលរួមនឹងផ្នែកល្បាក់ខោននៃទន្លេមេគង្គ។

ថ្ងៃទី២៣ ខែមិនា ឆ្នាំ២០០៦ រដ្ឋាភិបាលឡាវ និង វិស្វករជនជាតិម៉ាឡេស៊ី និង ក្រុមហ៊ុនវិនិយោគមួយ (Mega First Corporation Berhad, MFCB) បានចុះហត្ថលេខាលើ អនុសារណៈយោគយល់មួយចំពោះការស៊ើបអង្កេតទៅលើសេដ្ឋកិច្ច បរិស្ថាន និងលទ្ធភាពបច្ចេកទេសរបស់គម្រោងទំនប់វារីអគ្គិសនី **ដន សាហុង**។ អ្នកពិគ្រោះយោបល់ វាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA) PEC Konsult Sdn Bhd និង ក្រុមហ៊ុនថាមពល និង ទឹក នៃប្រទេសអូស្រ្តាលី (Austrian Power and Water) ត្រូវបានផ្តល់សិទ្ធិដោយ MFCB ចំពោះការសិក្សាពីគម្រោងទំនប់នេះ ហើយពង្រាងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA) មួយត្រូវបានគេចេញផ្សាយនៅ ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៧។ ការសិក្សាសមិទ្ធិលទ្ធភាពគឺត្រូវបានរៀបចំឡើងផងដែរ ដោយភ្ជាប់ជាមួយ EIA ហើយបានបញ្ចប់ក្នុងកំឡុង ខែតុលា ឆ្នាំ២០០៧។ ទោះជា EIA មិនត្រូវបានទទួលស្គាល់ក៏ដោយ កិច្ចព្រមព្រៀងអភិវឌ្ឍន៍គម្រោងមួយត្រូវបានចុះហត្ថលេខាដោយមានសញ្ញាព្រមានមួយថា EIA ដំបូងគួរត្រូវបានធ្វើឡើងវិញ។ បន្ទាប់មក ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៨ មានកិច្ចព្រមព្រៀងសម្បទានមួយចំពោះទំនប់នេះគឺត្រូវបានចុះហត្ថលេខារវាងប្រទេសឡាវនិង MFCB។

ក្នុងខែតុលា ឆ្នាំ២០១៣ រដ្ឋាភិបាលឡាវបានជូនដំណឹងទៅគណៈកម្មាការទន្លេមេគង្គ (MRC) ថាទំនប់ ដន សាហុង «គឺមិនស្ថិតនៅលើតួទន្លេមេនៃទន្លេមេគង្គទេ» ដែលគ្រាន់តែតម្រូវឲ្យមាន *«ការជូនដំណឹងជាមុន»* ជំនួសការ *«ការពិគ្រោះយោបល់មុន»*។ ផ្ទុយទៅវិញលេខាធិការដ្ឋាននៃគណៈកម្មការទន្លេមេគង្គ (MRC) បានបង្ហាញថា «ដន សាហុង គឺជាទំនប់ស្ថិតនៅលើតួទន្លេមេនៃទន្លេមេគង្គ» ដែលមានទាំងក្នុងផែនការអភិវឌ្ឍន៍អាង

(BDP) និងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានជាយុទ្ធសាស្ត្រ(SEA) នៃទំនប់ស្ថិតនៅលើតួទន្លេមេនៃទន្លេមេគង្គផង។ ឯកសារទាំងអស់នេះក៏ត្រូវបានយល់ព្រមដោយរដ្ឋាភិបាលឡាវផងដែរ។ ទាំងនេះបង្ហាញថារដ្ឋាភិបាលឡាវមិនបានគោរពតាមកិច្ចព្រមព្រៀងមេគង្គឆ្នាំ១៩៩៥ ដែលបានចុះហត្ថលេខាដោយប្រទេសទាំងបួនក្នុងតំបន់ទន្លេមេគង្គក្រោមដែលទទួលស្គាល់ពីសារៈសំខាន់នៃការប្រើប្រាស់ទន្លេរួមគ្នានេះឲ្យប្រកបដោយចីរភាពឡើយ។

រហូតមកដល់បច្ចុប្បន្ននេះ មិនទាន់មានការបង្ហាញអំពីឆន្ទៈរបស់ប្រទេសឡាវ ក្នុងការពិគ្រោះយោបល់ជាមួយរាជរដ្ឋាភិបាលកម្ពុជា និងប្រជាពលរដ្ឋដែលរស់តាមដងទន្លេមេគង្គនៅកម្ពុជាឡើយ។ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានជាបណ្តុំ បានបង្ហាញថា មិនទាន់មានការពិគ្រោះយោបល់ជាសាធារណៈផ្លូវការ រឺការប្រជុំណាមួយដើម្បីផ្តល់ព័ត៌មានដល់អាជ្ញាធរដែលពាក់ព័ន្ធអំពីការសាងសង់ទំនប់ដនសាហុងនោះឡើយ។ លើសពីនេះទៀត ការសិក្សាថ្មីៗរបស់ IFReDI បានគូសបញ្ជាក់ពីការផ្លាស់ប្តូរយ៉ាងខ្លាំងក្នុងការនេសាទត្រីទឹកសាបដោយសារតែការអភិវឌ្ឍទំនប់វារីអគ្គិសនីលើតួទន្លេមេនៃទន្លេមេគង្គ ដែលអាចមានផលប៉ះពាល់អវិជ្ជមានលើសន្តិសុខស្បៀង អាហាររូបត្ថម្ភ និងសុខភាពសាធារណៈ។ របកគំហើញនៃការស្រាវជ្រាវមួយទៀតស្តីពី «ទន្លេសាបនាពេលបច្ចុប្បន្ន និងអនាគត» បានបង្ហាញថាការអភិវឌ្ឍទំនប់វារីអគ្គិសនីលើតួទន្លេមេនៃទន្លេមេគង្គគឺរំពឹងថានឹងផ្តល់ផលប៉ះពាល់ជាចំបងលើ បរិស្ថាន សង្គម និងសេដ្ឋកិច្ច នៃប្រព័ន្ធបឹងទន្លេសាប។

អាស្រ័យដូច្នេះហើយទើប វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា សហការជាមួយ សម្ព័ន្ធទន្លេកម្ពុជា (RCC) ដើម្បីរៀបចំសិក្ខាសាលាថ្នាក់ជាតិមួយស្តីពី «ការព្រួយបារម្ភណ៍ចំពោះទំនប់វារីអគ្គិសនីដន សាហុង» សម្រាប់អ្នកពាក់ព័ន្ធរួមមាន រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ ស្ថាប័នស្រាវជ្រាវ អង្គការក្រៅរដ្ឋាភិបាល តំណាងសហគមន៍ ពិភាក្សាពីសារៈសំខាន់នៃទន្លេមេគង្គ និងបញ្ហាប្រឈមមុខចំពោះជីវភាពរបស់ពួកគាត់ដែលអាចប៉ះពាល់ពីទំនប់នេះ។ គោលបំណងចំបងនៃសិក្ខាសាលានេះគឺចែករំលែកព័ត៌មាន បង្កើនការស្វែងយល់ពីទំនប់ ដន សាហុង និងផលប៉ះពាល់ជាអាទិភាពរបស់វាចំពោះជីវភាពសហគមន៍ដែលរស់នៅតាមបឹងទន្លេសាប និងទន្លេមេគង្គ។

## ២. គោលបំណង

១. ដើម្បីបង្កើនចំណេះដឹងសិក្ខាកាមលើគម្រោងទំនប់វារីអគ្គិសនី ដន សាហុង ក្នុងប្រទេសនៃតំបន់ទន្លេមេគង្គ។
២. ដើម្បីចែករំលែកព័ត៌មានក្នុងចំណោមរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ ស្ថាប័នស្រាវជ្រាវ អង្គការក្រៅរដ្ឋាភិបាល តំណាង សហគមន៍ អំពីគម្រោងទំនប់វារីអគ្គិសនី ដន សាហុង និង ផលប៉ះពាល់ចំបងៗរបស់វា។
៣. ដើម្បីបើកវេទិកាសម្រាប់សិក្ខាកាម ជាពិសេស សហគមន៍ ដើម្បីពិភាក្សាអំពីផលប៉ះពាល់ និងកង្វល់ពីគម្រោងទំនប់វារីអគ្គិសនី ដន សាហុង និងដើម្បីស្វែងរកយុទ្ធសាស្ត្រធ្វើការរួមគ្នាទាក់ទងនឹងគម្រោងទំនប់នេះ។

## ៣. លទ្ធផលរំពឹងទុក

១. សិក្ខាកាមនឹងបានកើននូវចំនេះដឹងស្តីពីគម្រោងទំនប់វារីអគ្គិសនី ដន សាហុង ក្នុងប្រទេសនៃតំបន់ទន្លេមេគង្គ។

២. សិក្ខាកាមនឹងទទួលបានព័ត៌មានបន្ថែមពីដៃគូពាក់ព័ន្ធដូចជា រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ ស្ថាប័នស្រាវជ្រាវ អង្គការក្រៅរដ្ឋាភិបាល តំណាងសហគមន៍ អំពីគម្រោងទំនប់វារីអគ្គិសនី ដន សាហុង និង ផលប៉ះពាល់ចំបងៗរបស់វាចំពោះមច្ឆាជាតិ និង ជីវភាពរស់នៅរបស់ពួកគេ។

៣. សហគមន៍មានឱកាសស្វែងយល់ពីចំណុចខ្វះខាតក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA) និង អាចលើកឡើងនូវការព្រួយបារម្ភណ៍ចំពោះទំនប់នេះ និងផលប៉ះពាល់របស់វាទៅលើជីវភាពរស់នៅរបស់ពួកគាត់ និងដើម្បីស្វែងរកយុទ្ធសាស្រ្តធ្វើការរួមគ្នាទាក់ទងនឹងគម្រោងទំនប់នេះ។

៤. មន្ត្រីរាជរដ្ឋាភិបាលនឹងមានការយល់ដឹងប្រសើរឡើង ចំពោះការព្រួយបារម្ភណ៍របស់សហគមន៍មូលដ្ឋាន ហើយនឹងចែករំលែកការព្រួយបារម្ភណ៍រួមទាំងយុទ្ធសាស្រ្តធ្វើការរួមគ្នាទាំងនេះជាមួយអ្នកធ្វើសេចក្តីសំរេចចិត្តកំពូល។

**៤. របៀបវារៈ:**

| ពេលវេលា | ប្រធានបទ | វាគ្មិន/អ្នកសម្របសម្រួល |
|---|---|---|
| 7:30-8:00 | ការចុះឈ្មោះ | |
| 8:00-8:05 | គោរពភ្លេងជាតិ | MC |
| 8:05-8:15 | សន្ទរកថាស្វាគមន៍ និងគោលបំណងនៃសិក្ខាសាលា | លោក តឹក វណ្ណារ៉ា នាយកប្រតិបត្តិ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា |
| 8:15-8:20 | ចំណាប់អារម្មណ៍សហគមន៍លើសិក្ខាសាលានេះ | អ្នកស្រី បួរ ខាំតង តំណាងសហគមន៍ |
| 8:20-8:40 | សន្ទរកថាបើកសិក្ខាសាលា | ឯកឧត្តម **ទា ផុប** អនុរដ្ឋលេខាធិការ ក្រសួងបរិស្ថាន |
| 8:40-8:50 | ថតរូបជាក្រុមអនុស្សាវរីយ៍ | |
| ផ្នែក ១៖ ស្ថានភាពបច្ចុប្បន្ននៃទំនប់ ដន សាហុង និងផលប៉ះពាល់ចំបងៗ<br>សម្របសម្រួលដោយ ៖ លោក យុក សេងឡុង, FACT | | |
| 8:50-9:15 | ការណែនាំ និងបច្ចុប្បន្នភាពនៃទំនប់ ដនសាហុង | ឯកឧត្តម តែ ណាវុធ អគ្គលេខាធិការ នៃគណៈកម្មាធិការជាតិ ទន្លេមេគង្គកម្ពុជា |

| | | |
|---|---|---|
| 9:15-9:45 | ទស្សនកិច្ចសិក្សានៅទំនប់ដនសាហុង និងទស្សនៈសង្គមស៊ីវិលលើទំនប់នេះ | លោក តឹក វណ្ណារ៉ា<br>នាយកប្រតិបត្តិ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា |
| 9:45-10:15 | ផលប៉ះពាល់នៃទំនប់ដនសាហុងទៅលើផ្សោតមេគង្គ | លោក ហៀវី ផេន<br>ទីប្រឹក្សាបច្ចេកទេស WWF |
| 10:15-10:30 | សម្រាក (អាហារសម្រន់) | |
| 10:30-11:00 | សំណួរ ចំលើយ | |
| **ផ្នែក ២៖ សារៈសំខាន់នៃការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន និងគុណភាព**<br>**សម្របសម្រួលដោយ ៖ លោកស្រី អ៊ឹម ផលឡៃ NGOF** | | |
| 11:00-11:25 | សារៈសំខាន់នៃការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន | លោក ដាញ់ សេរី<br>អនុប្រធាននាយកដ្ឋានEIA នៃក្រសួងបរិស្ថាន |
| 11:25-11:45 | របាយការណ៍វិភាគស្តីពី EIA នៃទំនប់ដនសាហុង | កញ្ញា អេមី ជ្រេនឌឹម, ទន្លេអន្តរជាតិ |
| 11:45-12:00 | សំណួរ ចំលើយ | |
| 12:00-13:30 | សម្រាកអាហារថ្ងៃត្រង់ (ផ្តល់ជូន) | |
| **ផ្នែក ៣៖ ពិភាក្សាក្រុម និងជំហានបន្ទាប់ស្តីពីទំនប់ដនសាហុង**<br>**ណែនាំវិធីសាស្ត្រក្រុមពិភាក្សាដោយ៖ លោកស្រី ជា ផល្លីកា**<br>**សម្របសម្រួលដោយ៖ លោក ចាយ គាថា និង លោក មាន ចំរើន (អ្នកស្រាវជ្រាវ), លោក ម៉េងហាក់ វិឆ្ល័យ និង កញ្ញា ចេង ស្រីមុំ (សហគមន៍), លោកស្រី លុយ រស្មី និង លោក ម៉ៅ ប៉ម (សង្គមស៊ីវិល), និង កញ្ញា ថៃ សុដា និង លោក ស៊ុន គីមហឿន (រដ្ឋាភិបាល)** | | |
| 13:30-14:30 | **សំណួរចំបង ២ (World Coffee – ៤ ក្រុម)**<br>១.តើអ្នកមានការព្រួយបារម្ភយ៉ាងដូចម្តេចខ្លះចំពោះទំនប់វារីអគ្គីសនីដនសាហុង?សូមកំណត់បញ្ហាបីដែលជាអាទិភាព<br>២.តើយើងត្រូវតែធ្វើអ្វីខ្លះដើម្បីដោះស្រាយបញ្ហាអាទិភាពទាំងបីនោះ? កំណត់ដំណោះស្រាយបីដែលជាអាទិភាព | សិក្ខាកាមទាំងអស់ |
| 14:30-15:30 | ជំហានបន្ទាប់ (វេទិកាពិភាក្សារួម)<br>**វាគ្មិន៖** ៥នាទីសម្រាប់ម្នាក់ស្តីពីការដោះស្រាយការព្រួយបារម្ភ | អ្នកសម្របសម្រួល៖<br>លោក ហម គីមគង់, |

| | | |
|---|---|---|
| | ដែលបានលើកឡើងចំពោះចំនុចអាទិភាពទាំងបីៈ<br>១. តំណាងរដ្ឋាភិបាល (tbc)<br>២. តំណាងអ្នកស្រាវជ្រាវ<br>៣. តំណាងសង្គមស៊ីវិល លោក ខាំ ស៊ីងួន<br>៤. តំណាងសហគមន៍ អ្នកស្រី សោ សុន្ទរី | RUPP |
| 15:30-16:00 | សម្រាក (អាហារសម្រន់) | |
| 16:00-16:30 | សេចក្តីថ្លែងការណ៍រួម | លោក ចាន់ ធឿង<br>តំណាងសហគមន៍ |
| 16:30-16:40 | សន្ទរកថាបិទ សិក្ខាសាលា | លោកស្រី លុយ រស្មី<br>គណៈកម្មការគ្រប់គ្រង ស ម្ព័ន្ធទន្លេកម្ពុជា |

គណៈកម្មការរៀបចំសូមរក្សាសិទ្ធិក្នុងការកែប្រែកម្មវិធី

ឧបសម្ពន្ធ័ ៖ សេចក្តីថ្លែងការរួម

## សេចក្តីថ្លែងការរួម
## សិក្ខាសាលាថ្នាក់ជាតិ ស្តីពី ការព្រួយបារម្ភណ៍ចំពោះគម្រោងទំនប់វារីអគ្គិសនី
## «ដន សាហុង»
## ថ្ងៃ២០ ខែមីនា ឆ្នាំ២០១៤

# សូមគោរពជូន

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**
**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រថៃឡង់**
**នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋសង្គមនិយមវៀតណាម**
**នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ**

ទំនប់វារីអគ្គិសនី **ដនសាហុង** ដែលមានថាមពល ២៦០ម៉េហ្គាវ៉ាត់ គឺជាទំនប់មួយក្នុងចំណោមគម្រោងទំនប់វារីអគ្គិសនីទាំង១២ដែលគ្រោងសាងសង់នៅតួទន្លេមេនៃទន្លេមេគង្គក្រោម។ បច្ចុប្បន្នវាកំពុងត្រូវបានចាប់ផ្តើមសិក្សា និងដាក់សំណើសម្រាប់ការសាងសង់បន្ទាប់ពីទំនប់វារីអគ្គិសនី សាយ៉ាបូរី។ វាមានទីតាំងស្ថិតនៅចំងាយ ២ គីឡូម៉ែត្រ ពីព្រំដែនកម្ពុជា-ឡាវ ក្នុងខេត្ត ចំប៉ាសាក់ ប្រទេសឡាវ។ អគ្គិសនីបានពីទំនប់ដងសាហុង ត្រូវបានគ្រោងទុកសំរាប់នាំចេញទៅកាន់ប្រទេសថៃ។ ប្រសិនបើទំនប់ត្រូវបានសាងសង់វានឹងរាំងខ្ទប់ដៃទន្លេ ហ៊ូ សាហុង ដែលជាដៃទន្លេដ៏ធំមួយដែលរួមនឹងផ្នែកល្បាក់ខោននៃទន្លេមេគង្គក្រោម។

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា សហការជាមួយសម្ព័ន្ធទន្លេកម្ពុជា (RCC) បានរៀបចំសិក្ខាសាលាថ្នាក់ជាតិមួយស្តីពី «ការព្រួយបារម្ភណ៍ចំពោះទំនប់វារីអគ្គិសនីដនសាហុង» នៅថ្ងៃទី២០ ខែមីនា ឆ្នាំ ២០១៤ ដើម្បីផ្តល់ឱកាសសម្រាប់អ្នកពាក់ព័ន្ធរួមមាន រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ ស្ថាប័នស្រាវជ្រាវ អង្គការក្រៅរដ្ឋាភិបាល តំណាងសហគមន៍ ពិភាក្សាពីសារៈសំខាន់នៃទន្លេមេគង្គ និងបញ្ហាប្រឈមមុខ ចំពោះជីវភាពរបស់ពួកគាត់ដែលអាចប៉ះពាល់ពីទំនប់ ដន សាហុង។

គោលបំណងចំបងនៃសិក្ខាសាលានេះ គឺចែករំលែកព័ត៌មាន បង្កើនការស្វែងយល់ពីទំនប់ ដនសាហុង និងផលប៉ះពាល់ជាអាទិភាពរបស់វាចំពោះជីវភាពសហគមន៍ដែលរស់នៅតាមបឹងទន្លេសាប និងទន្លេមេគង្គ។ នៅក្នុងពេលដំណើរការសិក្ខាសាលា អ្នកចូលរួមបានលើកឡើងពីក្តីបារម្ភលើផលប៉ះពាល់ដែលអាចកើតមានពីទំនប់ ដែលផលប៉ះពាល់ទាំងនោះរួចបញ្ចូលទាំងផលប៉ះពាល់លើជីវភាពរស់នៅប្រចាំថ្ងៃ និងសុវត្ថិភាពស្បៀង ការបាត់បង់នូវធនធានធម្មជាតិ បញ្ហាសន្តិសុខ និងហានិភ័យផ្សេងៗ បញ្ហាសុខភាពសហគមន៍ និងកង្វះភាពនៃគុណភាព

របស់ការសិក្សាពីផលប៉ះពាល់ និងការពិគ្រោះយោបល់ជាមួយសហគមន៍។ អ្នកចូលរួមក៏លើកឡើងនូវសំណូមពរល្អៗជាច្រើនផងដែរ សូមពិនិត្យមើលក្នុងឯកសារភ្ជាប់ពីក្តីបារម្ភ និងសំណូមលំអិតបន្ថែមទៀត។

*"ប្រសិនបើទំនប់ ដន សាហុង ត្រូវបានសាងសង់ នាងខ្ញុំមានក្តីបារម្ភថា នឹងមិនមានត្រីសម្រាប់នេសាទទេ ហើយនាងខ្ញុំគឺមិនអាចចិញ្ចឹមកូនៗរបស់ខ្ញុំបានដែរ។ នាងខ្ញុំមានការព្រួយបារម្ភពីអនាគតរបស់នាងខ្ញុំណាស់"។* អ្នកស្រី ប្អូ ខាំតង, តំណាងសហគមន៍មកពីខេត្តស្ទឹងត្រែង

*"ប្រសិនបើទំនប់ ដន សាហុង ត្រូវបានសាងសង់ពិតមែន ប្រទេសឡាវនឹងបាត់បង់សត្វផ្សោតជារៀងរហូត ហើយសត្វផ្សោតដែលនៅសល់នៅប្រទេសកម្ពុជានឹងបន្តបាត់បង់ផងដែរ!"* លោក ជើរ វ៉ាយអេន, ទីប្រឹក្សាបច្ចេកទេសរបស់ WWF កម្ពុជា

*"គ្មានផ្សោត គឺគ្មានទេសចរណ៍ ហើយក៏មិនមានចំណូលដែរ"* លោក ផ្លយ វណ្ណា តំណាងសហគមន៍ខេត្តក្រចេះ

*" យើងមិនអាចរស់នៅបានដោយគ្មានត្រីបានទេ ប៉ុន្តែ យើងអាចរស់នៅបាន ដោយគ្មានអគ្គិសនី"* លោក ឡុង សូចែត តំណាងបណ្តាញប្រជានេសាទ បឹងទន្លេសាប

យើងខ្ញុំទាំងអស់គ្នាសង្ឃឹមថា រាល់បញ្ហា និងក្តីបារម្ភ ក៏ដូចជាសំណូមពរ ដែលបានលើកឡើងខាងលើនេះ រាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា ប្រទេសឡាវ ប្រទេសវៀតណាម និងប្រទេសថៃ នឹងទទួលយកទៅពិចារណានៅក្នុង កិច្ចប្រជុំកំពូលរបស់គណៈកម្មាធិការទន្លេមេគង្គ លើកទីពីរ នៅប្រទេសវៀតណាម នៅថ្ងៃទី៥ ខែមេសា ឆ្នាំ ២០១៨ខាងមុខនេះ។

- បញ្ឈប់ជាបន្ទាន់នូវវឌ្ឍនភាពទាំងអស់ស្តីពីទំនប់វារីអគ្គិសនី ដន សាហុង រហូតដល់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែនប្រកបដោយការត្រិះរិះបានបង្កើតឡើង។
- ទាមទារការពិគ្រោះយោបល់ដោយមានអត្ថន័យពេញលេញ និងតម្លាភាពព័ត៌មានជាមួយ សហគមន៍ដែលប៉ះពាល់ដោយសារគម្រោង។
- ស្នើឲ្យរដ្ឋាភិបាល MRC អំពាវនាវឲ្យមានការពិគ្រោះយោបល់ជាមុនដោយគោរពទៅតាមកិច្ចព្រមព្រៀងមេគង្គ ឆ្នាំ១៩៩៥។

**ព័ត៌មានបន្ថែមសូមទំនាក់ទំនងមក៖**

១. អ្នកស្រី ប្អូ ខាំតង តំណាងសហគមន៍ទន្លេមេគង្គ, ទូរស័ព្ទ៖០៩៧ ៩៨១៣១៥៤

២. លោក តឹក វណ្ណារ៉ា តំណាងអង្គការសង្គមស៊ីវិល, ទូរស័ព្ទ៖ ០១២ ៧៩៣ ៤៨៩

៣. លោក ឡុង សូចែត តំណាងបណ្តាញប្រជានេសាទ បឹងទន្លេសាប, ទូរស័ព្ទ៖ ០១២ ៩៨៩ ៣១៨

**ឯកសារភ្ជាប់ សម្រាប់ព័ត៌មានលំអិតចំពោះ សេចក្តីថ្លែងការរួម**

**តំណាងសហគមន៍**

**ការព្រួយបារម្ភ**

**១. ជីវភាព**

- បាត់បង់ប្រាក់ចំណូលពីការនេសាទ
- ប្រាក់ចំណូលពីទេសចរណ៍
- ប្រាក់ចំណូលពីរបរកសិកម្ម
- ពិបាកក្នុងការ ផ្លាស់ទីលំនៅ ដោយបាត់បង់ជីវភាព និងមិនប្រាកដពីអ្នក**ទទួលខុសត្រូវ**

**២. សុខភាព**

- ខូចគុណភាពទឹក ដែលនាំអ្នកភូមិមានជំងឺ
- ទឹកមានមេរោគ
- គុណភាពទឹកមិនល្អ ខ្វះអនាម័យ
- កង្វះជីវជាតិ និង ប្រូតេអ៊ីន (អត់ត្រី នាំឲ្យខ្វះអាហារបរិភោគ)

**៣. ធនធានធម្មជាតិ**

- បាត់បង់ធនធានជលផល
- បំផ្លាញ និង បាត់បង់អន្លុងផ្សោត
- បាត់បង់ផ្សោត
- បាត់បង់ដីមានជីជាតិ ពិសេសដីល្បាប់
- បាត់បង់ដីស្រែចំការ និងសត្វពេលមានទឹកជំនន់ និង ការបើកទឹករហ័ស
- ការកាប់បំផ្លាញព្រៃឈើ នាំឲ្យបាត់បង់ធនធានព្រៃ
- បាត់បង់ត្រី និង សត្វពាហនៈ
- បាត់បង់ជីវៈចំរុះ
- កំរិតទឹកមិនទៀងទាត់
- បាត់បង់ពូជត្រីសំខាន់ៗ
- ប៉ះពាល់ដល់ការធ្វើចរាចររបស់ត្រី
- ផលប៉ះពាល់អាចរិតតែធ្វើឲ្យមានបញ្ហាធ្ងន់ធ្ងរដល់ការប្រែប្រួលអាកាសធាតុ

**៣. សន្តិសុខ សង្គម និង វប្បធម៌**

- សុខភាព និងសន្តិសុខស្បៀង នឹងមានបញ្ហាដោយសារការបាត់បង់ចរាចរត្រី

- បំផ្លាញសាមគ្គីភាពសហគមន៍ និង ការអនុវត្តប្រពៃណី វប្បធម៌
- បែកបាក់សហគមន៍ តាមរយៈការបំលាស់ទី បាត់បង់ការរៀនសូត្រ
- បាត់បង់ទ្រព្យសម្បត្តិ ដោយសារជំនន់យ៉ាងគំហុក
- រងគ្រោះពីការបាក់ទំនប់វារីអគ្គិសនី ឬបើកបង្ហូរទឹកពីទំនប់វារីអគ្គិសនី
- បាត់បង់ផ្លូវនាវាចរ

**សំណូមពរ**

- ស្នើសុំឲ្យមានការពិគ្រោះយោបល់ជាមួយសហគមន៍ (ផ្តល់ព័ត៌មានឲ្យបានគ្រប់គ្រាន់ដល់សហគមន៍)
- ស្នើឲ្យរាជរដ្ឋាភិបាលកម្ពុជាពិភាក្សាជាមួយរដ្ឋាភិបាលឡាវ ដើម្បីសិក្សាស្រាវជ្រាវពីផលប៉ះពាល់ឲ្យបានស៊ីជម្រៅ

***ផែនការសកម្មភាព***

- ធ្វើសេចក្តីថ្លែងការដាក់ជូនរដ្ឋាភិបាល (ដោយមានស្នាមមេដៃគាំទ្រពីសហគមន៍)
- ធ្វើការផ្សព្វផ្សាយដល់សហគមន៍ពីទំនប់ដនសាហុង
- ធ្វើសន្និសីតកាសែតបង្ហាញពីការព្រួយបារម្ភ
- ដង្ហែរក្បួនយកសេចក្តីថ្លែងការទៅដាក់ជូននាយករដ្ឋមន្ត្រី

<u>**តំណាង សង្គមស៊ីវិល**</u>

**ការព្រួយបារម្ភ**

- ការពិគ្រោះយោបល់ និងការផ្សព្វផ្សាយនូវព័ត៌មានទាក់ទងនឹងគម្រោងទំនប់ដនសាហុង គឺនៅមានកំរិត ឬមិនមានការពិគ្រោះយោបល់ណាមួយបានកើតឡើងជុំវិញទំនប់ដនសាហុងនេះ
- សហគមន៍ទទួលបានព័ត៌មានតិចតួច ឬ ស្ទើរតែគ្មានពីទំនប់នេះធ្វើឲ្យមានការពិបាកក្នុងការធ្វើការតស៊ូមតិ
- បាត់បង់នូវធនធានធម្មជាតិ ប្រព័ន្ធអេកូឡូស៊ី និងជីវៈចំរុះប្រសិនបើទំនប់វារីអគ្គិសនី ដន សាហុង ត្រូវបានសាងសង់
- មានផលប៉ះពាល់ឆ្លងដែន
- ផលប៉ះពាល់ខ្លាំងបំផុតទៅដល់ត្រី និងផ្លូវចរាចររបស់ត្រី
- របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA) គឺមានការខ្វះចន្លោះច្រើន រួមទាំងមិនបានរួមបញ្ចូលអ្នកពាក់ព័ន្ធ ជាពិសេសជាមួយ សហគមន៍រងផលប៉ះពាល់
- គម្រាមកំហែងដល់សន្តិសុខស្បៀង សុខភាព និង បាត់បង់ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាប្រមាណ៦ លាននាក់
- មិនច្បាស់អំពីយន្តការក្នុងការស្តារសុវត្ថិភាពស្បៀង និង ការបាត់បង់ជីវភាពរស់នៅ

- ធ្វើឲ្យមានការរើតាំងទីលំនៅសម្រាប់សហមន៍រស់នៅក្បែរតំបន់ទំនប់
- មិនមានផែនការផ្តល់សំណង និង ការរុះរើលំនៅថ្មី សម្រាប់សហគមន៍ដែលរស់ពឹងអាស្រ័យលើទន្លេមេគង្គ
- ធ្វើឲ្យមានការប្រែប្រួលនូវលំហូរទឹកដែលធ្វើឲ្យមានផលប៉ះពាល់អវិជ្ជមានដល់ដីល្បាប់ ដែលមានជីជាតិសំខាន់សម្រាប់ការងារកសិកម្ម
- ការបំពុលទឹកធ្វើឲ្យប៉ះពាល់ដល់តួទន្លេមេ និង ទន្លេមេគង្គផ្នែកខាងក្រោម
- បំផ្លាញតំបន់រ៉ាមសារ
- បាត់បង់ចំណូលសេដ្ឋកិច្ចដោយសារផលប៉ះពាល់ជលផល ទេសចរណ៍ ការផ្លាស់ទីលំនៅ
- រដ្ឋាភិបាលមិនបានបង្ហាញនូវគោលជំហច្បាស់លាស់លើការព្រួយបារម្ភរបស់សហគមន៍
- តើមានសហគមន៍ប៉ុន្មានក្នុងប្រទេសកម្ពុជាដែលបានយល់ច្បាស់ពីផលប៉ះពាល់របស់ទំនប់ សាយ៉ាបូរី និងទំនប់ ដន សាហុង ទៅលើជីវិតរស់នៅរបស់ពួកគេ
- ធ្វើយ៉ាងណាដើម្បីឲ្យរដ្ឋាភិបាលឡាវពិចារណា និងយកចិត្តទុកដាក់ពីផលប៉ះពាល់អវិជ្ជមានដែលនឹងកើតមានដល់ប្រទេសផ្នែកខាងក្រោម

**ជំហានបន្ទាប់**

- លើកកម្ពស់ការយល់ដឹងដល់ប្រជាជនតាមសហគមន៍អំពីផលប៉ះពាល់អវិជ្ជមានរបស់ទំនប់
- លើកកម្ពស់ សមត្ថភាពសហគមន៍គោលដៅ និងពង្រឹងបណ្តាញ
- ចែករំលែកបទពិសោធន៍ពីផលប៉ះពាល់ឆ្លងដែន
- រាជរដ្ឋាភិបាលគួរតែធ្វើការសិក្សាអំពីក្តីកង្វល់របស់សហគមន៍លើគម្រោងទំនប់
- ស្វែងរក និងប្រមូលភស្តុតាងសំខាន់ៗបន្ថែមទៀតសំរាប់គាំទ្រសកម្មភាពតស៊ូមតិ
- តស៊ូមតិជាមួយរាជរដ្ឋាភិបាលកម្ពុជាលើសេរីភាពនៃការបញ្ចេញមតិ
- ផ្សព្វផ្សាយតាមរយៈវិទ្យុ និងទូរទស្សន៍អំពីការអភិវឌ្ឍន៍ទំនប់ និងផលប៉ះពាល់
- ស្វែងរកវិធីសាស្ត្រដែលមានប្រសិទ្ធិភាពបំផុតដើម្បីផ្សារភ្ជាប់ទំនាក់ទំនងព័ត៌មានទៅនឹងការតស៊ូមតិ ដើម្បីធ្វើការតស៊ូមតិជាមួយអ្នកគាំទ្រទំនប់
- ស្វែងរកមធ្យោបាយដែលមានប្រសិទ្ធភាពបំផុតដើម្បីពាំនាំនូវក្តីបារម្មណ៍ទាំងឡាយពាក់ព័ន្ធ ទំនប់អោយបានដល់ថ្នាក់ដឹកនាំទន្លេមេគង្គ
- គាំទ្រអោយមានការលើកឡើងនូវក្តីបារម្មណ៍អំពីទំនប់ និងធ្វើអោយប្រាកដថារដ្ឋាភិបាលមានអន្តរអំពើជាមួយសហគមន៍
- លើកឡើងនូវយុទ្ធនាការណាមួយដើម្បីទប់ស្កាត់ការអភិវឌ្ឍទំនប់ និងជ្រើសរើសជម្រើសថាមពលកកើតឡើងវិញ

**<u>តំណាងក្រុមសិក្សាស្រាវជ្រាវ</u>**

**ការព្រួយបារម្ភណ៍**

- បាត់បង់ចរាចរណ៍ត្រី
- បាត់បង់ប្រភេទត្រី
- បាត់បង់ផ្សោត
- ទំនប់វារីអគ្គិសនីនឹងរាំងខ្ទប់លំហូរដីល្បាប់
- បញ្ហាសុខភាព និងសន្តិសុខស្បៀង
- បាត់បង់ដីលំនៅឋាន
- ផ្លាស់ប្តូរគុណភាពទឹក
- ការវាយតម្លៃហេតុប៉ះពាល់មានកំសោយភាព និងចំណុចខ្វះចន្លោះច្រើន
- គ្មានការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន
- គ្មានតម្លាភាព និងទំនួលខុសត្រូវស្តីពីការចែករំលែកប្រយោជន៍
- ប៉ះពាល់លើការអនុវត្តវប្បធម៌នឹងទំនៀមទំលាប់ និងបេតិកភ័ណ្ឌក្នុងតំបន់

**ជំហានបន្ទាប់**

- ផ្តល់ជំនាញបច្ចេកទេសទៅឲ្យប្រជាជនក្នុងតំបន់ដើម្បីបង្កើនការបន្សុំាវិស័យកសិកម្មរបស់ពួកគេ
- បង្កើតការ សិក្សា EIA ឆ្លងដែនដែលទូលំទូលាយ
- បង្កើតការពិគ្រោះយោបល់ជាមួយគ្រប់ភាគីពាក់ព័ន្ធ